01008548

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 15 / 08 / 2014
ម៉ោង (Time/Heure) : 11 : 50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E314

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អនុស្សរណៈអន្តរការិយាល័យ - អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤

**ជូនចំពោះ៖** ឯកឧត្តម តង់ ស្រ៊ឹម ប្រធានគណៈកម្មាធិការរដ្ឋបាលតុលាការ

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង និងភាគីទាំងអស់ក្នុងសំណុំរឿង ០០២/០២

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** សំណើសុំឲ្យបង្កើតក្រុមប្រឹក្សាជំនុំជម្រះមួយដើម្បីសម្រេចលើពាក្យបណ្តឹងរបស់ នួន ជា ប្តឹងជំទាស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង

កាលពីថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានទទួលសារអេឡិចត្រូនិក (email) មួយពីក្រុមមេធាវីការពារក្តី នួន ជា ជូនដំណឹងដល់អង្គជំនុំជម្រះអំពីចេតនារបស់ពួកគេក្នុងការប្តឹងជំទាស់ចៅក្រមដែលមានរាយឈ្មោះដូចតទៅនេះ មិនឲ្យជំនុំជម្រះជាបន្តទៀតក្នុងសំណុំរឿង ០០២ ៖ ចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម យូរ ឧត្តរា។ ក្រុមមេធាវីការពារក្តី នួន ជា មិនប្តឹងជំទាស់ចៅក្រម Silvia CARTWRIGHT ទេ ដោយសារថា លោកស្រីចៅក្រមនឹងឈប់បំពេញការងារនៅ អ.វ.ត.ក នៅមុនថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤ នេះហើយ។ ក្រុមមេធាវីការពារក្តី នួន ជា គ្រោងថានឹងដាក់ពាក្យបណ្តឹងរបស់ខ្លួនក្នុងពេលឆាប់ៗនេះ នៅមុន ឬនៅថ្ងៃច័ន្ទ ទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៤ និងបញ្ជាក់ថា បណ្តឹងនេះស្របទៅនឹងវិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង។ ក្រុមមេធាវីការពារក្តី នួន ជា ស្នើសុំបន្ថែមចំនួនទំព័រកំណត់រហូតដល់ ៣០ ទំព័រ ជាភាសាអង់គ្លេស និងស្នើសុំការអនុញ្ញាតដាក់ពាក្យបណ្តឹងជំទាស់របស់

ខ្លួនជាភាសាអង់គ្លេសជាមុនសិន រីឯការបកប្រែជាភាសាខ្មែរនឹងត្រូវដាក់ជូនតាមក្រោយឱ្យបានឆាប់ តាមដែលអាចធ្វើទៅបាន។

អនុលោមតាមវិធាន ៣៤(៦) នៃវិធានផ្ទៃក្នុង ប្រសិនបើមានពាក្យបណ្តឹងជំទាស់ចំពោះចៅក្រមច្រើននាក់ ដែលមិនអាចរៀបចំអង្គជំនុំជម្រះដើម្បីសម្រេចលើពាក្យបណ្តឹងនោះបានទេ គណៈកម្មាធិការរដ្ឋបាលតុលាការ (“JAC”) ត្រូវជ្រើសរើសចៅក្រមបន្ថែមពីក្នុងចំណោមចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញ។

ក្នុងខណៈដែលមិនទាន់មានពាក្យបណ្តឹងជំទាស់នេះនៅឡើយនោះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា បញ្ហាជាក់លាក់មួយចំនួន ដែលក្រុមមេធាវីការពារក្តី នួន ជា បានលើកឡើងនៅក្នុងសារអេឡិចត្រូនិករបស់ខ្លួន អាចតម្រូវឱ្យមានការពិចារណាដោយក្រុមចៅក្រមដែលនឹងចាត់តាំងឡើងដោយ JAC នៅមុនពេលចៅក្រមទាំងនោះ ទទួលបានពាក្យបណ្តឹងជំទាស់។

ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងស្នើឱ្យ JAC បង្កើតក្រុមប្រឹក្សាជំនុំជម្រះមួយ ដែលមានសមាសភាពពីក្នុងចំណោមចៅក្រមរបស់ អ.វ.ត.ក ដើម្បីដោះស្រាយលើបញ្ហាទាំងឡាយដែលក្រុមមេធាវីការពារក្តី នួន ជា បានលើកឡើងនៅក្នុងសារអេឡិចត្រូនិក និងដោះស្រាយទៅលើបណ្តឹងជំទាស់នៅពេលទទួលបានបណ្តឹងនោះ។ អង្គជំនុំជម្រះសាលាដំបូងមិនបានដឹងទេ ថាតើភាគីដទៃទៀតមានបំណងប្តឹងជំទាស់ចៅក្រមដូចដែលបានរៀប-រាប់ឈ្មោះខាងលើ ដូចក្រុមមេធាវីការពារក្តី នួន ជា ដែរ ឬ ក៏មានបំណងប្តឹងជំទាស់ចៅក្រមដទៃបន្ថែមទៀត ឬយ៉ាងណានោះឡើយ។ សារអេឡិចត្រូនិកពីក្រុមមេធាវីការពារក្តី នួន ជា ត្រូវបានភ្ជាប់មកជាមួយអនុស្សរណៈនេះ។